# សន្លឹកព័ត៌មានសាធារណៈ

Ottawa County Health Department

## រោគសាលាទែន [MUMPS]

**ឥតើរោគសាលាទែនគឺជាអ្វី?**

រោគសាលាទែនគឺជារោគស្រាលមួយ បង្កដោយវីរុសមួយ ។

**តើរោគសាលាទែនត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?**

រោគសាលាទែនអាចឆ្លងបាន តាមរបៀបទាំងឡាយខាងក្រោមនេះ:

- ដំណក់ទឹកតូចល្អិតពីច្រមុះ និងបំពង់ក របស់អ្នកមានរោគសាលាទែន
- ប៉ះពាល់របស់របរដែលមានដំណក់ទឹកតូចល្អិតទាំងនេះនៅលើវា

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញាមានរួមទាំង:

- គ្រន្ថិនៅក្រោមត្រចៀក និងមុខក ហើម ហើយឈឺ
- ក្តៅខ្លួន និងរងា
- ឈឺក្បាល
- សម្រាប់បុរស ឈឺពងស្វាសមួយ ឬទាំង ពីរ

**តើរោគសាលាទែនត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**

ដោយពិនិត្យខ្លួន និងពិនិត្យឈាម ។

**តើរោគសាលាទែនត្រូវបានព្យាបាលយ៉ាងដូចម្តេច?**

- គ្មានវិធីព្យាបាលរោគសាលាទែនពិតប្រាកដទេ ។ អ្នកមានរោគសាលាទែន ត្រូវតែនៅផ្ទះ កុំទៅធ្វើការ ឬសាលារៀន អស់រយ:ពេល 9 ថ្ងៃក្រោយពីចាប់ផ្តើមហើម ។
- អាចប្រើថ្នាំថៃឡិនណល់ សម្រាប់ការឈឺ និងកំដៅខ្លួន ។ ការបរិភោគអាហារទន់ៗ អាចជួយបន្ថយការឈឺចាប់បាន ។

**តើរោគសាលាទែនអាចបង្ការបានយ៉ាងដូចម្តេច?**

- ថ្នាំបង្ការរោគសាលាទែនត្រូវបានចាក់ពីអាយុ 12-15 ខែ និងម្តងទៀតនៅអាយុ 4-5 ឆ្នាំ ជាផ្នែកមួយនៃថ្នាំបង្ការ MMR ។ ថ្នាំបង្ការពីរកម្រិត មានប្រសិទ្ធិភាព 90% ក្នុងការបង្ការរោគសាលាទែន ។ ជនពេញវ័យដែលកើតមុនឆ្នាំ 1957 ត្រូវបានចាត់ទុកថាស៊ាំជម្ងឺ ។

**សម្រាប់ព័ត៌មានបន្ថែមអំពីរោគសាលាទែន:**

Ottawa County Health Department
www.miOttawa.org
Center for Disease Control and Prevention
www.cdc.gov/nip/diseases/mumps/default.htm
ទូរស័ព្ទ: (888) 246-2675